# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្ដាហ៍ លេខ ៦៣

អង្គជំនុំជម្រះសាលាដំបូង បានដោះស្រាយនូវបញ្ហាជាច្រើនដែលកើតមានក្នុងសប្ដាហ៍នេះ មានដូចជាការបិទបញ្ចប់ការស្ដាប់ព្យសនកម្មរបស់ជនរងគ្រោះដែលបានបន្តកាលពីសប្ដាហ៍មុន និងសវនាការដាក់បង្ហាញឯកសារគន្លឹះ ស្ដីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង។[1] ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបីរូប បានផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទ ពាក់ព័ន្ធទៅនឹងសេចក្ដីទុក្ខវេទនាដែលពួកគាត់បានឆ្លងកាត់ ដែលជាលទ្ធផលបានមកពីការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា និងមន្ទីរសន្តិសុខ ស-២១។ នៅថ្ងៃអង្គារ មេធាវីការពារក្ដីឲ្យជនជាប់ចោទលោក ខៀវ សំផន បានធ្វើបទបង្ហាញអំពីសារណាឆ្លើយតបទៅនឹងឯកសារគន្លឹះដែលបានដាក់បង្ហាញកាលពីសប្ដាហ៍មុនដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ នៅថ្ងៃពុធ អង្គជំនុំជម្រះសាលាដំបូង បានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីថ្មីមួយរូបមានរហស្សនាម **2-TCCP-1040** ដែលបានផ្ដល់សក្ខីកម្មក្រោមការប្រើប្រាស់ឈ្មោះជារហស្សនាមនេះ ស្ដីពីការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា និងការបះបោររបស់ **សៅ ភឹម**។[2] នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះ បានស្ដាប់សក្ខីកម្មរបស់សាក្សីផ្សេងមួយទៀត ស្ដីពី

[1] ផ្នែកទីមួយនៃសវនាការស្ដាប់ព្យសនកម្មរបស់ជនរងគ្រោះ និងសវនាការលើឯកសារគន្លឹះ សម្រាប់ផ្នែកជំនុំជម្រះនេះ ត្រូវបានរាយការណ៍ក្នុងរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៦២ ស្ដីពីសវនាការលើកស្ដុតាង សប្ដាហ៍ទី៥៩ (ចុះថ្ងៃទី១១ ដល់ទី១២ ខែសីហា ឆ្នាំ២០១៦)។

[2] ការប្រើប្រាស់ឈ្មោះជារហស្សនាម ត្រូវបានចាត់ទុកថាជាការចាំបាច់ ដោយអង្គជំនុំជម្រះសាលាដំបូង ពីព្រោះបុគ្គលរូបនេះកំពុងស្ថិតក្នុងផ្នែកមួយនៃការបន្តកិច្ចស៊ើបអង្កេតរបស់ **អ.វ.ត.ក**។ ព័ត៌មានលម្អិតផ្ទាល់ខ្លួនដែលជាទូទៅត្រូវបានដាក់បង្ហាញជាសាធារណៈនូវឈ្មោះ

អង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង គឺលោក **សួយ សៅ** ដែលសក្ខីកម្មនៅក្នុងសវនាការរបស់គាត់ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងទៅនឹងព័ត៌មានដែលគាត់បានផ្ដល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៩ ម៉្លោះហើយ អង្គជំនុំជម្រះ បានសម្រេចធ្វើសវនាការជាអសាធារណៈ ក្នុងគោលបំណងស្វែងរកថាតើមានបញ្ហាត្រង់ប្រការណាមួយកើតឡើងទៅលើសក្ខីកម្មរបស់គាត់។[3] មានបញ្ហាផ្នែកច្បាប់ជាច្រើន បានកើតមានឡើងនាសប្ដាហ៍នេះ រួមមាន៖ ការជំទាស់នឹងសំណួរដែលក្រៅពីវិសាលភាពនៃការជំនុំជម្រះ ការប្រើប្រាស់នូវឯកសារមួយជាក់លាក់ធ្វើជាភស្តុតាង និងការរក្សាភាពសម្ងាត់នៃអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី **2-TCCP-1040**។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ប្រ៊ីតនី អូលីណា ឆៅ (Britni Olina Chau), ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), និន វុទ្ធី, តាយ លីណា, ធំ ស្ដាពរ, អាលីណា យូត្រាតា (Alina Utrata) និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់បែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម បែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

បុគ្គល ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងប្រវត្តិរូបរបស់ក្រុមគ្រួសារ ត្រូវបានរក្សាការសម្ងាត់។ ទោះបីជាមានវិធានការណ៍បែបនេះក៏ដោយ ក៏ព័ត៌មានជាក់លាក់មួយចំនួនស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានទម្លាយឲ្យដឹងក្នុងវគ្គនៃការផ្ដល់សក្ខីកម្មរបស់ពួកគាត់ផងដែរ។

[3] លោក **សួយ សៅ** ត្រូវបានស្នើសុំដោយក្រុមមេធាវីការពារឲ្យជនជាប់ចោទលោក **នួន ជា** នៅខែមីនា ឆ្នាំ២០១៦ ជាផ្នែកមួយនៃសំណើសុំកោះហៅសាក្សីបន្ថែម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតផ្ទៃក្នុង។ សូមមើលឯកសាររបស់ក្រុមមេធាវីការពារក្ដីឲ្យជនជាប់ចោទលោក **នួន ជា** "សំណើរបស់ **នួន ជា** អនុលោមវិធាន ៨៧ (៤) សុំកោះហៅសាក្សីបន្ថែម និងសំណើអនុលោមតាមវិធាន ៨៧ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទងនឹងវគ្គសវនាការនៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតផ្ទៃក្នុង" (ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦) ឯកសារលេខ E391។